# យល់ដឹងសិទ្ធិរបស់អ្នក

## ការថែទាំដែលបញ្ជាក់យេនឌ័រ

## ការថែទាំដែលបញ្ជាក់យេនឌ័រគឺស្របច្បាប់ និងត្រូវបានការពារនៅក្នុងរដ្ឋវ៉ាស៊ីនតោន

### រដ្ឋវ៉ាស៊ីនតោនការពារសិទ្ធិទទួលបានការថែទាំដែលបញ្ជាក់យេនឌ័រ៖[1]

- ក្រុមហ៊ុនធានារ៉ាប់រងសុខភាព និងគម្រោងសុខភាពមិនត្រូវរើសអើងតាមមធ្យោបាយណាមួយ ដោយផ្អែកលើនិន្នាការផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់បុគ្គលនោះទេ។
- រដ្ឋវ៉ាស៊ីនតោនហាមមិនឱ្យក្រុមហ៊ុនធានារ៉ាប់រងសុខភាព និងគម្រោងសុខភាពដែលមានការធានារ៉ាប់រងពេញលេញធ្វើការបដិសេធ ឬកំណត់ការធានារ៉ាប់រងសម្រាប់ការថែទាំដែលបញ្ជាក់យេនឌ័រសម្រាប់មនុស្សគ្រប់វ័យ នៅពេលដែលត្រូវបានចេញវេជ្ជបញ្ជាជាចាំបាច់ផ្នែកវេជ្ជសាស្ត្រស្របតាមការបង្ហាញយេនឌ័រ ឬអត្តសញ្ញាណយេនឌ័ររបស់បុគ្គលម្នាក់ និងស្របតាមស្តង់ដានៃការថែទាំដែលទទួលយកបាន។[2]
- ការបដិសេធ ឬការកំណត់បែបនេះត្រូវបានហាមឃាត់ លុះត្រាតែអ្នកផ្តល់សេវាថែទាំសុខភាពដែលមានបទពិសោធចេញវេជ្ជបញ្ជា ឬផ្តល់ការថែទាំដែលបញ្ជាក់យេនឌ័របានពិនិត្យ និងបញ្ជាក់ថាការបដិសេធ ឬការកំណត់គឺធ្វើឡើងក្រោមហេតុផលវេជ្ជសាស្ត្រសមស្រប។
- អាយុអាចជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលត្រូវបានពិចារណាដើម្បីកំណត់ថាតើនីតិវិធីមួយគឺចាំបាច់ផ្នែកវេជ្ជសាស្ត្រឬអត់ និងត្រូវបានចេញវេជ្ជបញ្ជាឱ្យស្របតាមស្តង់ដានៃការថែទាំដែលទទួលយកបាន។[3]
- ក្រុមហ៊ុនធានារ៉ាប់រងសុខភាព និងគម្រោងសុខភាពមិនអាចអនុវត្តការលើកលែងប្រភេទកែសម្ផស្ស ឬគោលការណ៍ទូទៅ ដើម្បីបដិសេធលើការថែទាំដែលបញ្ជាក់យេនឌ័រ នៅពេលចេញវេជ្ជបញ្ជាចាំបាច់ផ្នែកវេជ្ជសាស្ត្រនោះទេ។
- Washington Health Care Authority (HCA, អាជ្ញាធរថែទាំសុខភាពនៃរដ្ឋវ៉ាស៊ីនតោន), គម្រោងថែទាំដែលគ្រប់គ្រងដោយ Medicaid និងអ្នកផ្តល់សេវាថែទាំសុខភាពដែលផ្តល់ ឬគ្រប់គ្រងសេវាតាមរយៈ HCA មិនអាចរើសអើងក្នុងការគ្រប់គ្រង ឬការផ្តល់សេវាថែទាំដែលបញ្ជាក់យេនឌ័រដោយផ្អែកលើអត្តសញ្ញាណ ឬការបង្ហាញយេនឌ័ររបស់អ្នកដែលមានការធានារ៉ាប់រងនោះទេ។[4]
- កម្មវិធី Medicaid របស់រដ្ឋវ៉ាស៊ីនតោន, Apple Health រ៉ាប់រងលើការថែទាំដែលបញ្ជាក់យេនឌ័រ នៅពេលដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រ សុវត្ថិភាព ប្រសិទ្ធភាព និងមិនមែនជាការពិសោធ។[5]
- គម្រោងសុខភាពរបស់និយោជិតរដ្ឋរួមបញ្ចូលច្បាស់លាស់នូវការធានារ៉ាប់រងសម្រាប់ការថែទាំដែលបញ្ជាក់យេនឌ័រ។[6]
- នៅរដ្ឋវ៉ាស៊ីនតោន នេះជាការប្រព្រឹត្តិដែលគ្មានវិជ្ជាជីវៈសម្រាប់អ្នកផ្តល់សេវាក្នុងការព្យាបាលដោយកែប្រែអត្តសញ្ញាណយេនឌ័ររបស់អ្នកជំងឺដែលមានអាយុក្រោម 18 ឆ្នាំ។[7]
- អ្នកផ្តល់សេវាថែទាំសុខភាព ក្រុមហ៊ុនធានារ៉ាប់រង និងមណ្ឌលថែទាំ មិនចាំបាច់ផ្តល់ ឬឱ្យមូលនិធិសម្រាប់ការថែទាំដែលបញ្ជាក់យេនឌ័រ ក្រោមហេតុផលនៃភាពត្រឹមត្រូវ ឬហេតុផលសាសនាឡើយ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងសុខភាពត្រូវតែបញ្ជាក់អំពីសេវាដែលមិនត្រូវបានរ៉ាប់រង និងរបៀបដែលបុគ្គលនោះនៅតែអាចទទួលបានការថែទាំឆាប់រហ័ស។[8]

### រដ្ឋវ៉ាស៊ីនតោនការពារពលរដ្ឋនៅរដ្ឋវ៉ាស៊ីនតោន ពីការប្រព្រឹត្តកម្រិតរដ្ឋប្បវេណី និងព្រហ្មទណ្ឌនៅក្នុងរដ្ឋផ្សេងទៀតដែលដាក់កម្រិត ឬដាក់ទោសចំពោះការថែទាំដែលបញ្ជាក់យេនឌ័រ៖

- Shield Law (ច្បាប់ខែលការពារ) របស់រដ្ឋវ៉ាស៊ីនតោនការពារយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋនៅរដ្ឋវ៉ាស៊ីនតោនពីការស៊ើបអង្កេត ឬដំណើរការរបស់តុលាការនៅក្នុងរដ្ឋមួយផ្សេងទៀតដែលពាក់ព័ន្ធនឹងការថែទាំដែលបញ្ជាក់យេនឌ័រស្របច្បាប់ដែលផ្តល់ជូននៅរដ្ឋវ៉ាស៊ីនតោន។[9]
- ជាទូទៅ Shield Law ហាមតុលាការរដ្ឋវ៉ាស៊ីនតោន ទាំងភ្នាក់ងាររដ្ឋ និងតាមមូលដ្ឋាន និងការអនុវត្តច្បាប់ ព្រមទាំងក្រុមហ៊ុន ឬអង្គភាពឯកជនដែលមានមូលដ្ឋាននៅរដ្ឋវ៉ាស៊ីនតោនពីការចាប់ខ្លួន ការផ្តល់ព័ត៌មាន ឬការចូលរួម ឬអនុវត្តតាមដំណើរការផ្លូវច្បាប់របស់រដ្ឋផ្សេងទៀតដែលទាក់ទងនឹងការថែទាំដែលបញ្ជាក់យេនឌ័រស្របច្បាប់ដែលផ្តល់ជូននៅក្នុងរដ្ឋវ៉ាស៊ីនតោន។

---

1 សូមមើលឧទាហរណ៍ Revised Code of Washington (RCW, ក្រមដែលបានកែប្រែនៃរដ្ឋវ៉ាស៊ីនតោន) 48.43.0128; Washington Administrative Code (WAC, ក្រមរដ្ឋបាលនៃរដ្ឋវ៉ាស៊ីនតោន) 284-43-5151; RCW 49.60.030(e); RCW 49.60.040(27); RCW 49.60.178(1); RCW 48.30.300(1), (2)។

2 គម្រោងសុខភាពដែលប្រើប្រាស់ថវិកាផ្ទាល់ខ្លួនដែលត្រូវបានចេញដោយផ្ទាល់ដោយនិយោជកក្រៅពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពត្រូវបានគ្រប់គ្រងដោយ Employee Retirement Income Security Act (ERISA, ច្បាប់ស្តីពីសន្តិសុខចំណូលពីការចូលនិវត្តរបស់និយោជិត) និងស្របទៅតាមបទប្បញ្ញត្តិប្រឆាំងនឹងការរើសអើងនៃ Affordable Care Act (ច្បាប់ថែទាំដែលមានតម្លៃសមរម្យ) (ផ្នែក 1557)។ ប្រសិនបើអ្នកមិនប្រាកដថាគម្រោងរបស់អ្នកត្រូវបានធានារ៉ាប់រងពេញលេញ ឬប្រើប្រាស់ថវិកាផ្ទាល់ខ្លួនទេ អ្នកអាចទាក់ទងស្នងការធានារ៉ាប់រងរដ្ឋវ៉ាស៊ីនតោន (ទំនាក់ទំនងព័ត៌មានខាងក្រោម) ហើយពួកគេអាចជួយអ្នកបាន។

3 អាចពិគ្រោះជាមួយក្រុមហ៊ុនធានាសុខភាព ឬគម្រោងសុខភាពបាន នៅពេលកំណត់ថាតើនីតិវិធីថែទាំដែលបញ្ជាក់យេនឌ័រត្រូវបានចេញវេជ្ជបញ្ជាស្របតាមស្តង់ដានៃការថែទាំដែលទទួលយកបានឬអត់។ ឧទាហរណ៍ ស្តង់ដានៃការថែទាំទាំងនោះដែលត្រូវបានបោះពុម្ពផ្សាយដោយ World Professional Association for Transgender Health (WPATH)។

4 RCW 74.09.675(1).

5 WAC 182-531-1675(1).

6 សូមមើល Transgender Legal Defense & Education Fund គម្រោងសុខភាពនិយោជិតរដ្ឋ – រដ្ឋវ៉ាស៊ីនតោន https://transhealthproject.org/resources/state-employee-health-plans/washington-state-employee-health-plans/

7 RCW 18.130.180(26); Tingley v. Ferguson, 47 F.4th 1055, 1063–64 (9th Cir. 2022), cert. denied, 144 S. Ct. 33, 217 L. Ed. 2d 251 (2023).

8 RCW 18.130.160.

9 RCW 7.115.020.

- Shield Law ក៏ការពារអ្នកផ្តល់សេវាថែទាំសុខភាពនៅរដ្ឋវ៉ាស៊ីនតោនពីការគំរាមកំហែង និងការបៀតបៀនដោយឱ្យពួកគេ និងសមាជិកគ្រួសាររបស់ពួកគេមានសិទ្ធិចូលរួម Address Confidentiality Program (កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន) របស់រដ្ឋវ៉ាស៊ីនតោន។
- ច្បាប់នេះអនុញ្ញាតឱ្យបុគ្គលម្នាក់ប្ដឹងមន្ត្រីក្រៅរដ្ឋពីបទជ្រៀតជ្រែកលើសេវាថែទាំសុខភាពដែលត្រូវបានការពាររបស់បុគ្គលម្នាក់នៅក្នុងរដ្ឋវ៉ាស៊ីនតោន។[10]
- អាចស្វែងរកព័ត៌មានបន្ថែមអំពី Shield Law របស់រដ្ឋវ៉ាស៊ីនតោននៅទីនេះ៖ https://www.atg.wa.gov/reproductive-and-gender-affirming-care-shielding-providers-seekers-and-helpers-out-state-legal

### រដ្ឋវ៉ាស៊ីនតោនការពារសិទ្ធិទទួលបានព័ត៌មានសុខភាពឯកជនរបស់យុវជន៖

- ជំរំសម្រាប់យុវជនដែលមានអាជ្ញាបណ្ណក្នុងរដ្ឋវ៉ាស៊ីនតោនត្រូវបានហាមឃាត់មិនឱ្យទាក់ទងឪពុកម្ដាយ ឬអាណាព្យាបាលរបស់យុវជនដែលស្នាក់នៅក្នុងជំរំឡើយ នៅពេលដែលយុវជនកំពុងស្វែងរកការថែទាំដែលបញ្ជាក់យេនឌ័រ។
- ជំនួសមកវិញ ជំរំយុវជនដែលមានអាជ្ញាបណ្ណត្រូវតែទាក់ទងទៅ Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ) ក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីយុវជនមកដល់ជំរំ៖[11]
- បុគ្គលិកសាលារដ្ឋនៃរដ្ឋវ៉ាស៊ីនតោនមិនអាចចែករំលែកព័ត៌មានសុខភាពសម្ងាត់ ឬព័ត៌មានអប់រំរបស់សិស្សណាមួយ (រួមទាំងអ្នកប្តូរភេទ ឬស្ថានភាពមិនអនុលោមតាមយេនឌ័ររបស់សិស្ស ឬភេទដែលបានកំណត់ពីកំណើត) ជាមួយអ្នកផ្សេងទៀត រួមទាំងឪពុកម្តាយរបស់សិស្ស សិស្សផ្សេងទៀត បុគ្គលិកសាលា ឬបុគ្គលក្រៅសាលាបានទេ លុះត្រាតែតម្រូវដោយច្បាប់[12] ឬលុះត្រាតែសិស្សបានផ្តល់ការអនុញ្ញាតឱ្យចែករំលែក។[13]

### បណ្ដឹងតវ៉ា ឬកង្វល់អំពីការបំពានច្បាប់រដ្ឋ?

- Apple Health (Medicaid) និង Public Employees Benefits Board (PEBB, ក្រុមប្រឹក្សាអត្ថប្រយោជន៍បុគ្គលិកសាធារណៈ) និង School Employees Benefits Board (SEBB, អ្នកជាវកម្មវិធីក្រុមប្រឹក្សាអត្ថប្រយោជន៍បុគ្គលិកសាលា) សូមទាក់ទងអ្នកសម្របសម្រួលផ្នែក Americans with Disabilities Act (ADA, ច្បាប់ស្ដីពីជនជាតិអាមេរិកដែលមានពិការភាព) របស់អាជ្ញាធរថែទាំសុខភាព៖
  ប្រព័ន្ធអនឡាញ៖ https://support.hca.wa.gov/hcasupport។
  ទូរសព្ទ៖ 855-682-0787។
  អ៊ីមែល៖ compliance@hca.wa.gov
- អ្នកជាវគម្រោងថែទាំសុខភាពរបស់រដ្ឋផ្សេងទៀតទាំងអស់ សូមទាក់ទង៖
  - Office of the Insurance Commissioner (ការិយាល័យស្នងការធានារ៉ាប់រង)៖ ទូរសព្ទ៖ 800-562-6900។ ទូរសព្ទសម្រាប់ TDD៖ 360-586-0241។
    ប្រព័ន្ធអនឡាញ៖ https://www.insurance.wa.gov/complaints-appeals-fraud/complaints
  - Washington State Human Right Commission (គណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋវ៉ាស៊ីនតោន)៖ ទូរសព្ទ៖ 800-233-3247។ ប្រព័ន្ធអនឡាញ៖ https://wahum.my.site.com/FileaComplaintOnline/s/?language=en_US
  - Attorney General's Office (ការិយាល័យអគ្គរដ្ឋអាជ្ញា)៖ ទូរសព្ទ (ក្នុងរដ្ឋ WA)៖ 800-551-4636។ ទូរសព្ទ (ក្រៅរដ្ឋ WA)៖ 206-464-6684។ សេវាបញ្ជូនបន្ត៖ 800-833-6388។
    ប្រព័ន្ធអនឡាញ៖ https://www.atg.wa.gov/contactus.aspx
- ចំពោះបណ្ដឹងតវ៉ា ឬកង្វល់ទាក់ទងនឹងសាលារដ្ឋនៃរដ្ឋវ៉ាស៊ីនតោន សូមទាក់ទងទៅ Washington State Office of the Superintendent of Public Instruction's Equity and Civil Rights Office (ការិយាល័យសមធម៌ និងសិទ្ធិស៊ីវិលរបស់ការិយាល័យអគ្គនាយកភ្នាក់ងារអប់រំសាធារណៈរដ្ឋវ៉ាស៊ីនតោន) តាមរយៈលេខ (360) 725-6162/TTY៖ (360) 664-3631។

### កន្លែងដែលត្រូវស្វែងរកអ្នកផ្តល់សេវាថែទាំសុខភាពដែលបញ្ជាក់យេនឌ័រ

- https://lgbtqhealthcaredirectory.org/

---

10 RCW 7.115.040.

11 សូមមើល RCW 13.32A.082(1)(b), (2)(c)-(d).

12 ឧទាហរណ៍ Federal Educational Rights and Privacy Act (FERPA, ច្បាប់ស្ដីពីសិទ្ធិ និងឯកជនភាពនៃការអប់រំសហព័ន្ធ) អាចតម្រូវឱ្យមានការបង្ហាញព័ត៌មានជាក់លាក់។ 20 United States Code (U.S.C, ក្រមនៃសហរដ្ឋអាមេរិក) § 1232g; 34 Code of Federal Regulations (C.F.R, ក្រមនៃបទប្បញ្ញត្តិសហព័ន្ធ) ផ្នែកទី 99។

13 Equity and Civil Rights Office, Washington State Office of the Superintendent of Public Instruction ការហាមឃាត់ការរើសអើងនៅក្នុងសាលារដ្ឋនៃរដ្ឋវ៉ាស៊ីនតោន – គោលការណ៍ណែនាំសម្រាប់មណ្ឌលសិក្សាធិការសាលារៀនដើម្បីអនុវត្តជំពូក 28A.640 និង 28A.642 RCW និងជំពូក 392-190 WAC, p. 29 (ខែកុម្ភៈ ឆ្នាំ 2012) (https://ospi.k12.wa.us/sites/default/files/2023-08/prohibiting_discrimination_in_washington_public_schools_february2012revisedsep2019disclaimer_1.pdf) (ចូលមើលចុងក្រោយថ្ងៃទី 17 ខែមិថុនា ឆ្នាំ 2024); សូមមើល RCW 28A.642.010; RCW 28A.642.020; RCW 28A.642.080 ផងដែរ។